**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍បាត់ដំបង**

សំណុំរឿងសភាព្រហ្មទណ្ឌលេខ ១៥០
ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២

**សាលដីកា**
លេខ ៨៥៩ "ញ"
ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍បាត់ដំបង**

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ ដោយមានសមាសភាពដូចខាងក្រោម ៖

17.10.22

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

| | | |
|---|---|---|
| **ឯកឧត្តម** | [redacted] | **ជាប្រធានក្រុមប្រឹក្សា** |
| **លោក** | [redacted] | **ជាចៅក្រមប្រឹក្សា** |
| **លោក** | [redacted] | **ជាចៅក្រមប្រឹក្សា** |

**<u>តំណាងមហាអយ្យការ</u>**

| | | |
|---|---|---|
| **លោក** | [redacted] | **ជាព្រះរាជអាជ្ញា** |

**<u>ក្រឡាបញ្ជីសវនាការ</u>**

| | | |
|---|---|---|
| **លោក** | [redacted] | **ជាក្រឡាបញ្ជីសាលាឧទ្ធរណ៍** |

ដើម្បីជំនុំជម្រះបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងសភាព្រហ្មទណ្ឌលេខ ១៥០ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ មានដូចខាងក្រោម ៖

១-ជនជាប់ចោទឈ្មោះ [redacted] ពៅ ភេទប្រុស ឆ្នាំកំណើត១៩៦០ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូមិស្វាយរលំក្រោម ឃុំព្រែកត្នោត ស្រុកស្អាង ខេត្តកណ្ដាល អាសយដ្ឋានបច្ចុប្បន្នភូមិពង្រ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ: [redacted] មានកូនចំនួន ០៣នាក់ ឪពុកឈ្មោះ: [redacted]ប) ម្តាយឈ្មោះ: [redacted] [redacted] (ស) ជានីតិជន ។ (ក្រៅឃុំ)



Scanned with CamScanner

ពីបទ ហិង្សាដោយចេតនា កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ ប្រព្រឹត្តនៅភូមិក្តុល ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]អេម ភេទស្រី អាយុ ៤៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិក្តុល ឃុំអំពិល ស្រុកបន្ទាយអំបិល ខេត្តឧមានជ័យ ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ មានករណីអំពើហិង្សាដោយចេតនាមួយបានកើតឡើងនៅភូមិក្តុល ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដែលបង្កឡើងដោយឈ្មោះ [redacted] ៣៧ ភេទប្រុស កើតឆ្នាំ១៩៦០ មុខរបរយោធាចូលនិវត្តន៍ រស់នៅភូមិទួលពង្រ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ ពីដំបូងជនរងគ្រោះឈ្មោះ [redacted]អេម ភេទស្រី បានអង្គុយលើអង្រឹងក្រោមផ្ទះ របស់ឈ្មោះ [redacted] សៀយ នៅភូមិឃុំកើតហេតុដូចខាងលើស្រាប់តែឈ្មោះ [redacted] ៣៧ ជិះម៉ូតូចូលទៅដល់និងបានហៅឈ្មោះ [redacted]អេម ទៅលាបប្រេងកូឡាឲ្យនិងបានហូបស្រាជាមួយតែឈ្មោះ [redacted]អេម បដិសេធក៏ធ្វើឲ្យឈ្មោះ [redacted] ៣៧ ខឹងហើយឈ្មោះ [redacted] ៣៧ ក៏ចាប់ឈ្មោះ [redacted]អេម គ្រញិច និងអោបថើបឈ្មោះ [redacted]អេម បានខំរើបំរាស់រួចពីដៃ [redacted] ៣៧ ក៏បានរត់ទៅដេកក្នុងអង្រឹងឆ្ងាយបន្តិច ហើយក៏ចាប់ផ្តើមមានទំនាស់ជេរប្រមាថគ្នាទៅវិញទៅមក បន្ទាប់មកឈ្មោះ [redacted] ៣៧ ក៏បានក្រោកទៅចាប់គ្រញិចលើឈ្មោះ [redacted]អេម ម្តងទៀតហើយចាប់កាច់ដៃឈ្មោះ [redacted] អេម ចំណែកឈ្មោះ [redacted] អេម ប្រឹងរើក៏បានធ្វើអោយឈឺដៃ និងឈឺខ្លួន ។ ទំនាស់របស់អ្នកទាំងពីរកើតឡើងដោយការប្រច័ណ្ឌ ទោះបីអ្នកទាំងពីរមិនបានរៀបការជាមួយគ្នាមែន តែធ្លាប់រួមរស់ជាមួយគ្នាដូចប្តីប្រពន្ធព្រោះកន្លងមកឈ្មោះ [redacted] ៣៧ បានប្រគល់កាតបើកប្រាក់យោធាចូលនិវត្តន៍របស់ខ្លួនឲ្យឈ្មោះ [redacted]អេម ទុក តែមួយរយៈចុងក្រោយនេះអ្នកទាំងពីរមានទំនាស់គ្នារស់នៅមិនចុះសម្រុងគ្នា ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១១៩ (ឈ)/១២០៥ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលសម្រេច ៖

I.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ៣៧ ភេទប្រុស កើតឆ្នាំ១៩៦០ ជាតិខ្មែរ (មានសារតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ ០១ (មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា ។

ពីបទ ហិង្សាដោយចេតនា កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ប្រព្រឹត្តនៅភូមិក្តុល ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ តាមបញ្ញាត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

II.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ៣៧ ភេទប្រុស សងជម្ងឺចិត្តចំនួន ២.០០០.០០០ (ពីរលាន)រៀល ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]រ៉ា ហៅ [redacted]អេម ។

III.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ និងប្រកាសសាលក្រមជាសាធារណៈនាថ្ងៃពុធ ៦កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។



Scanned with CamScanner

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៩ (ឆ)/៤៧៣ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលបានសម្រេច ៖

១/.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៩(ឈ)/១២០៥ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ ទុកជាបានការដដែល លើជនជាប់ចោទឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ ៦១ឆ្នាំ ប.ទ. ហិង្សាដោយចេតនា កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ប្រព្រឹត្តនៅភូមិគួល ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ហើយអំពើនេះត្រូវបានច្បាប់បញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២/.សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នាថ្ងៃអង្គារ ៤រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០២១ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ពៅ តែចាត់ទុកចំពោះមុខ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វីរ៉ា ហៅ [redacted] អេម ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អេម បានសុំប្តឹងឧទ្ធរណ៍លើសាលក្រមព្រហ្មទណ្ឌលេខ ៤៩ (ឆ)/៤៧៣ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះលេខ ១៥៩ ព្រទ.ឧបប/២២ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ របស់ប្រធានសាលាឧទ្ធរណ៍បាត់ដំបង ។

-បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមរបាយការណ៍ នៃសាលាឧទ្ធរណ៍បាត់ដំបង ។

-បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ពៅ (អវត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អេម (វត្តមាន)

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍រឿង ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អេម បានឆ្លើយបញ្ជាក់ថា ៖ ខ្លួនប្តឹងឧទ្ធរណ៍មិនសុខចិត្តរឿងសំណងតិចពេក ខ្លួនសុំទាមទារសំណង ៥,០០០ (ប្រាំពាន់)ដុល្លារ ខ្លួនអត់មានឯកសារព្យាបាលជម្ងឺទេ ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ រឿងនេះដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍លើសំណង គាត់មិនមានឯកសារណាមួយបញ្ជាក់ថាគាត់ចំណាយអស់ ៥,០០០ (ប្រាំពាន់)ដុល្លារនោះទេ ស្នើសុំដល់ក្រុមប្រឹក្សាពិចារណាសម្រេចជាក់ស្តែង ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាឧទ្ធរណ៍បាត់ដំបង**

**យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អេម បានសុំប្តឹងឧទ្ធរណ៍លើសាលក្រមព្រហ្មទណ្ឌលេខ ៨៩ (ឆ)/៨៧៣ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០២១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើង តាមកំណត់ច្បាប់ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បាត់ដំបងទទួលជំនុំជម្រះបានយោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-បណ្តឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] អេម ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ដូចនេះក្រុមប្រឹក្សា ពិចារណាតែទៅលើចំណុចសំណងរដ្ឋប្បវេណី នៃសេចក្តីសម្រេចប៉ុណ្ណោះ យោងតាមមាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-នាពេលសវនាការសាលាឧទ្ធរណ៍បាត់ដំបង ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អេម បានឆ្លើយបញ្ជាក់ថា ខ្លួនប្តឹងសុំទាមទារសំណងបន្ថែមចំនួន ៥០០០ដុល្លារអាមេរិក ប៉ុន្តែខ្លួនគ្មាន ឯកសារបញ្ជាក់អំពីស្ថានភាពរបួស និងការចំណាយផ្សេងៗទេ ករណីនេះក្រុមប្រឹក្សាមិនអាច ពិចារណាសម្រេចបានឡើយ ។

៤-ក្នុងរឿងក្តីនេះត្រូវបានសាលាដំបូងខេត្តបន្ទាយមានជ័យ លើកយកសំអាងហេតុមក បញ្ជាក់ត្រឹមត្រូវហើយ ក្រុមប្រឹក្សាឯកភាពលើសំអាងហេតុនោះ ដោយពុំចាំបាច់យកសំអាង ហេតុដដែលមកបញ្ជាក់សារជាថ្មីទៀតទេ ។

៥-សាលក្រមព្រហ្មទណ្ឌលេខ ៨៩ (ឆ)/៨៧៣ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលា ដំបូងខេត្តបន្ទាយមានជ័យ ដែលបានសម្រេចនេះមានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជា បានការដដែល ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] អេម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្លូវ នីតិគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៩ (ឆ)/៨៧៣ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការដដែល ។



Scanned with CamScanner

៣-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]អេម និងកំបាំងមុខជនជាប់ចោទឈ្មោ[redacted] ៣៧ ។

ទុកសិទ្ធិអោយប្តឹងទាស់ និងប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] , [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៩កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

បាត់ដំបង ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]